## តើអ្វីនឹងកើតឡើង បើសិនជាខ្ញុំគ្មានសមត្ថភាពដើម្បីបង់ថ្លៃយកកូនទៅចាក់ថ្នាំ វ៉ាក់សុីន បង្ការរោគបាននោះ ?

ថ្នាំ វ៉ាក់សុីន ជាទូទៅគឺចាក់ឲ្យក្មេងមិនយកថ្លៃឡើយ នៅពេលណាដែលឪពុកម្ដាយមិនអាចបង់ថ្លៃបាននោះ។ ទូរស័ព្ទមកលេខ 800-232-2522 ឬ ទាក់ទងមកក្រសួងសុខាភិបាលក្រុង ឬ រដ្ឋ ដើម្បីសាកសួរទីកន្លែងចាក់ថ្នាំ វ៉ាក់សុីន ដែលលោកអ្នកអាចយកទៅចាក់មិនគិតលុយ ឬបង់តម្លៃថោក ។ សុខភាពរបស់កូនលោកអ្នក គឺពឹងទាំងស្រុងទៅលើលោកអ្នកជាមាតាបិតា !

## ហើយនេះ គឺជាការរំលឹកដល់មាតាបិតា !

មនុស្សពេញវ័យ ក៏ត្រូវការចាក់បង្ការរោគដែរ ! ចូរទូរស័ព្ទមកមន្ទីរព្យាបាលរោគរបស់លោកអ្នក ឬ ក្រសួងសុខាភិបាល ដើម្បីសាកសួរគេនូវថ្នាំដែលលោកអ្នកត្រូវចាក់ ឬ នៅពេលណា ដល់ពេលកំណត់ចាក់ថ្នាំទៀតនោះ។ កូនរបស់លោកអ្នក គឺពឹងលើលោកអ្នកចំពោះសុខភាពល្អរបស់គេ !

ក្មេងទាំងអស់ដែល
មានអាយុពី 0-18 ឆ្នាំ ត្រូវតែ
ចាក់ថ្នាំ វ៉ាក់សុីន ការពាររោគ
រលាកថ្លើម B!




**មនុស្សគ្រប់រូបត្រូវចាក់ថ្នាំ វ៉ាក់សុីន បង្ការរោគ !**

បើសិនជាលោកអ្នកមិនអាចចេញថ្លៃចាក់ថ្នាំ ឬក៏មិនដឹងទៅចាក់នៅកន្លែងណា ចូរទាក់ទងមកទីក្រុងអ្នករស់នៅ. ខោនធី ឬ ក្រសួងសុខាភិបាលរដ្ឋ ឬ ទូរស័ព្ទមកលេខ 800-232-2522 ។



**Immunization Action Coalition**
1573 Selby Avenue, Suite 234
St. Paul, MN 55104
651-647-9009
www.immunize.org
www.vaccineinformation.org

ពាក្យពេចន៍នៅក្នុងកូនសៀវភៅនេះ បានពិនិត្យនិងកែតម្រូវឡើងវិញដោយ Centers for Disease Control and Prevention ។ កូនសៀវភៅនេះ គ្មានរក្សាសិទ្ធិទេ។ អាចកែប្រែឲ្យសមស្របសំរាប់ប្រើនៅមន្ទីរព្យាបាលរបស់លោកអ្នក ឬសេចក្ដីត្រូវការរបស់សហគមន៍។ តែបើសិនជាលោកអ្នកកែប្រែបន្ថែម សូមឲ្យគុណសម្បត្តិដល់ Immunization Action Coalition ដែលបានបង្កើតកូនសៀវភៅនេះ។

www.immunize.org/catg.d/4055ca.pdf
Item #P4055-03 Cambodian (4/98, reviewed 8/04)

# កូនក្មេងទាំងអស់ ត្រូវការចាក់ថ្នាំបង្ការ រលាកថ្លើម B !



ក្មេងតូចៗ



ក្មេងជំទង់



ហើយនិងក្មេងធំ, ផងដែរ !

## រោគរលាកថ្លើម B ជាអ្វី ?

រោគរលាកថ្លើម B ជាជម្ងឺថ្លើម ដែលកើតឡើងដោយសារមេរោគ។ មេរោគឆ្លងចូលតាមឈាម ហើយប្រឆាំងនិងថ្លើម ហើយធ្វើឲ្យកើតជម្ងឺធ្ងន់ធ្ងរ។ នៅក្នុងករណីខ្លះ មេរោគរស់នៅខ្លួនមនុស្សអស់មួយជីវិត ហើយធ្វើឲ្យមានបញ្ហាដល់ថ្លើមមិនឈប់មិនឈរទៀតផង។

## តើកូនក្មេង ហើយក្មេងជំទង់កើតរោគរលាកថ្លើម B តាមរបៀបណាដែរ ?

មានច្រើនប្រភេទណាស់។ រោគរលាកថ្លើម B អាចឆ្លងតាម :

- បន្ទះពាល់ឈាម ឬ រំអិលរបស់មនុស្សដែលមានរោគរលាកថ្លើម B
- ប្រើប្រាស់ដុះធ្មេញ ឡាមកោរពុកមាត់ ខោអាវបោក ឬ ប្រើម្ជុលចាក់ថ្នាំញៀនចូលគ្នា
- ខាំដោយមនុស្ស
- មានកាមគុណជាមនុស្សមានរោគថ្លើមនេះ
- ចោះត្រចៀក, ចោះសាច់ដាំក្រវែល ឬ សាក់ដោយប្រើសម្ភារៈក្រខ្វក់




## ហេតុដូចម្តេច បានជាកូនរបស់ខ្ញុំទាំងអស់ត្រូវការចាក់ថ្នាំបង្ការរោគរលាកថ្លើម B ?

ក្រុមផ្តល់សុខភាពធំៗនៅសហរដ្ឋអាមេរិក បានយល់ឃើញថា ក្មេងមានអាយុពី 0-18 ឆ្នាំទាំងអស់ត្រូវតែចាក់ថ្នាំបង្ការរោគរលាកថ្លើម B ដើម្បីជៀសវាងឲ្យផុតពីកើតរោគនេះ។ បច្ចុប្បន្ននេះ ទារកទាំងអស់គួរតែបានទទួលថ្នាំចាក់បង្ការរោគរលាកថ្លើម B ទទឹមនិងការចាក់ថ្នាំបង្ការរោគផ្សេងៗទៀត។ បើសិនជាកូន ហើយកូនជំទង់របស់លោកអ្នកមិនបានចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគរលាកថ្លើម B កាលពីនៅទារកនៅឡើយនោះទេ ចូរចាក់ថ្នាំវ៉ាក់ស៊ីននេះឲ្យវាភ្លាម។

## តើកូនខ្ញុំនឹងមានភាពកើតរោគរលាកថ្លើម B ច្រើនឬ?

អ្នកណាក៏អាចមានរោគរលាកថ្លើម B នេះដែរ។ តែចំពោះក្មេងដែលកើត ឬ មាតាបិតាក្មេងនោះកើតនៅបរទេស ដែលរោគរលាកថ្លើម B ជាជម្ងឺធ្ងន់ធ្ងរមួយ ប្រហែលជាអាចមានភាពកើតរោគរលាកថ្លើម B នេះច្រើន។

ទីកន្លែងខ្លះដែលរោគរលាកថ្លើម B ជាជម្ងឺមួយដ៏ធ្ងន់ធ្ងរនោះ គឺរួមចូលទាំងទ្វីបអាស៊ី, អាហ្វ្រិក, កោះនៅតាមមហាសមុទ្រ Pacific, អឺរ៉ុបខាងកើត, អតីតសហភាពសូវៀត ហើយនិងអាមេរិកខាងត្បូង។

បើសិនជាលោកអ្នកមិនដឹងច្បាស់លាស់អំពីសេចក្តីអន្តរាយពីរោគរលាកថ្លើម B នេះនៅប្រទេសដើមរបស់លោកអ្នកទេ ចូរសាកសួរវេជ្ជបណ្ឌិត ឬក្រសួងសុខាភិបាលសាធារណៈ។ វេជ្ជបណ្ឌិតរបស់លោកអ្នកប្រហែលជាត្រូវការពិនិត្យមើលកូនលោកអ្នក នៅពេលវាចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគលើកដំបូង ដើម្បីឲ្យបានដឹងច្បាស់ថា កូនលោកអ្នកមានកើតរោគរលាកថ្លើម B ឬអត់។




## តើគួរឲ្យខ្ញុំអនុញ្ញាតិកូនខ្ញុំចាក់ថ្នាំ វ៉ាក់ស៊ីន បង្ការរោគនៅសាលារៀនឬ ?

ភាគច្រើនក្មេងឥឡូវនេះ អាចចាក់ថ្នាំវ៉ាក់ស៊ីនបង្ការរោគរលាកថ្លើម B នៅសាលារៀនបាន។ បើសិនជាកូនលោកអ្នកអាចចាក់ថ្នាំវ៉ាក់ស៊ីននៅសាលារៀនបាន លោកអ្នកអាចបន្ធូរភារៈកិច្ចរបស់ខ្លួន ហើយ/ឬលោកអ្នកមិនពិបាកយកកូនទៅចាក់ថ្នាំបង្ការរោគនេះ នៅការិយាល័យវេជ្ជបណ្ឌិតបីដងនោះឡើយ !

## តើថ្នាំ វ៉ាក់ស៊ីន នេះ មានសន្តិសុខបែបណាដែរ ?




ថ្នាំចាក់វ៉ាក់ស៊ីនបង្ការរោគរលាកថ្លើម B គឺមានសន្តិសុខល្អណាស់។ ថ្នាំនេះបានប្រើនៅសហរដ្ឋអាមេរិកតាំងពីឆ្នាំ 1981 មកម្ល៉េះ ហើយក៏មានសន្តិសុខល្អព្រមទាំងគុណភាពល្អរហូតមក។